ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៛៛៛ ៙ ៛៛៛

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១៧៦ អយក.ប្រក

# ប្រកាស

## ស្តីពីការបើកថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការ

## មធ្យមសិក្សាទុតិយភូមិ ខេត្តកោះកុង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦.០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ. បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- តាមសំណើរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្តកោះកុង លេខ ០៦៦៦ អយក. ខកក. អកប ចុះថ្ងៃទី ២១ សីហា ២០០៦ ។
- តាមសំណូមពររបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ។

## សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យមន្ទីរអប់រំ យុវជន និង កីឡាខេត្តកោះកុង បើកថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការមធ្យមសិក្សាទុតិយភូមិ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ ដែលមានទីតាំងដូចខាងក្រោម :

- ស្រុកស្មាច់មានជ័យ ទីតាំងវិទ្យាល័យកោះកុង
- ស្រុកស្រែអំបិល ទីតាំងវិទ្យាល័យស្រែអំបិល

ប្រការ ២ : ថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការមធ្យមសិក្សាទុតិយភូមិទាំងពីរទីតាំងនេះ ត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់នៃមន្ទីរអប់រំ យុវជន និង កីឡាខេត្តកោះកុង ។

អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១៦
Email: crsmeys@camnet.com.kh Web site: www.moeys.gov.kg

ប្រការ ៣ : នាយក នាយករង និង បុគ្គលិកនៃសាលាដែលមានថ្នាក់បំពេញវិជ្ជា មានភារកិច្ចបន្ថែមក្នុងការគ្រប់គ្រង ដឹកនាំថ្នាក់បំពេញវិជ្ជានេះតាមការចាំបាច់ ។

ប្រការ ៤ : ប្រភពសិស្សចូលរៀនត្រូវទុកអាទិភាពឱ្យសិស្សរបស់សាលាផ្ទាល់ សិស្សដែលពុំបានរៀនបន្តនៅសាលាចំណេះទូទៅ ( ប្រឡងធ្លាក់២ដង) បុគ្គលិកអប់រំ និង មន្ត្រីរាជការដែលមានបំណងចង់រៀនសូត្របន្ថែម ។

ប្រការ ៥ : ប្រព័ន្ធអប់រំ កម្មវិធីសិក្សា និង បទបញ្ញត្តិផ្សេងៗ ត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកោះកុង និង នាយកថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការនេះមានភារកិច្ចអនុវត្តប្រកាសនេះរៀងៗខ្លួន ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ មករា ឆ្នាំ ២០០៧

ជ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ម៉ក់_វ៉ាន់

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- សាលាខេត្ត កោះកុង " ដើម្បីជ្រាបជាព័ត៌មាន "
- ដូចប្រការ ៧
- ឯកសារ
- កាលប្បវត្តិនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អាស្រ័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Web site: www.moeys.gov.kg